# **ការព្យាយាមចំពោះរឿងដ៏ពិចារក**

អែលឌើរ ចច អែហ្វ ស្បែបាលូស
នៃពួក 70 នាក់

*ជីវិតដ៏នៅអស់កល្បជានិច្ច គឺជាការរស់នៅជាមួយនឹងព្រះវរបិតា និងក្រុមគ្រួសាររបស់យើងជារៀងរហូត។ តើសេចក្ដីសន្យានេះពុំមែនជាគ្រឿងលើកទឹកចិត្តដ៏អស្ចារ្យបំផុតមួយ ដើម្បីធ្វើឱ្យអស់ពីលទ្ធភាពដែលយើងមាន នៅក្នុងការស្វែងរកអ្វីដែលត្រូវបានសន្យាថានឹងប្រទានឱ្យយើងទេឬអី?*

នៅពេលសិស្សទាំងដប់ពីរនាក់ត្រូវបានហៅនៅក្នុងទ្វីបអាមេរិក នោះព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ បានបញ្ជាដល់ពួកគាត់ថា: "ដូច្នេះ យើងចង់ឱ្យអ្នករាល់គ្នាបានល្អឥតខ្ចោះដូចជាយើង ឬដូចជាព្រះវរបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌ទ្រង់ល្អឥតខ្ចោះដែរ"។[1] ព្រះអង្គសង្គ្រោះបានបញ្ចប់បេសកកម្មរបស់ទ្រង់នៅលើផែនដីប្រកបដោយភាពជោគជ័យ គ្មានភាពអត្តានិយម និងមានការគិតគូរយ៉ាងល្អិតល្អន់។ ការណ៍នេះបានអនុញ្ញាតឱ្យទ្រង់ប្រកាសរួមជាមួយនឹង សិទ្ធិអំណាចថា ទ្រង់ ហើយនឹងព្រះវរបិតាទ្រង់ ដែលជាព្រះវរបិតាយើងផងដែរ គឺជាគំរូដែលយើងម្នាក់ៗគួរតែយកត្រាប់តាម។

ចេញពីទស្សនវិស័យដ៏បរិសុទ្ធមួយរបស់មនុស្ស ជាដំបូងបានគិតថា ការណ៏នេះមើលទៅមិនអាចនឹងប្រព្រឹត្តទៅបានឡើយ។ ប៉ុន្តែវាបានចាប់ផ្ដើមលេចឡើងជាលទ្ធភាពនៃការយល់ដឹងមួយថា យើងមិនបាននៅតែឯង ដើម្បីសំរេចកិច្ចការនេះឡើយ។ ជំនួយដ៏អស្ចារ្យ ហើយមានឥទ្ធិពលបំផុតដែលមនុស្សលោកស្វែងរក គឺមានជានិច្ច។ ទីមួយ គឺជាព្រះពាហុដែលមានក្ដីមេត្តា និងសេចក្ដី-ស្រឡាញ់របស់ព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ដែលទ្រង់មានព្រះរាជបំណងចង់ឱ្យយើង ត្រឡប់មកទីវត្តមានរបស់ទ្រង់ជានិច្ចនោះ។ ក្នុងនាមជាព្រះវរបិតារបស់យើង ទ្រង់តែងតែមានព្រះឆន្ទៈ និងព្រះរាជបំណង ដើម្បីអភ័យទោសចំពោះកំហុស និងភាពទន់ខ្សោយរបស់យើង ហើយនឹងអំពើបាបដែលយើងបានប្រព្រឹត្ត ដរាបណាយើងមានការប្រែចិត្តដោយស្មោះ និងពេញលេញប៉ុណ្ណោះ។ ហើយដើម្បីបំពេញបន្ថែម ចំពោះបញ្ហានោះ និងដើម្បីបង្ហាញពីសេចក្ដីស្រឡាញ់ដ៏ធំធេងរបស់ទ្រង់ចំពោះកូនចៅម្នាក់ៗនោះទ្រង់បានផ្ដល់ឱ្យយើង នូវលទ្ធផលដែលទទួលបានមកពីកិច្ចការដ៏អស្ចារ្យរបស់ព្រះអង្គសង្គ្រោះ ដែលមានឈ្មោះថា ដង្វាយធួនដែលបានធ្វើឡើងដោយព្រះរាជបុត្រាដែលមានការគោរពប្រតិបត្តិ ជាអង្គដែលតែងតែមានឆន្ទៈធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសំរាប់ជាប្រយោជន៏សំរាប់យើងម្នាក់ៗជានិច្ចនោះ។

ព្រះអម្ចាស់បានបើកសម្ដែងទៅកាន់ព្យាការីយ៉ូសែប ស្ម៊ីធ ដូចតទៅនេះថា : "ហើយបើសិនជាអ្នកកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត នោះអ្នកនឹងបានជីវិតដ៏នៅអស់កល្បជានិច្ច គឺជាអំណោយទានដ៏មហិមាបំផុតនូវគ្រប់អំណោយទានទាំងឡាយនៃព្រះ"។[2] សេចក្ដីសន្យាដ៏ទេវភាពនេះ គឺអាចសំរេចទៅបាន។ ជីវិតដ៏នៅអស់កល្បជានិច្ច គឺជាការរស់នៅជាមួយនឹងព្រះវរបិតា និងក្រុមគ្រួសាររបស់យើងជារៀងរហូត។ 3 តើសេចក្ដីសន្យានេះពុំមែនជាគ្រឿងលើកទឹកចិត្តដ៏អស្ចារ្យបំផុតមួយ ដើម្បីធ្វើអ្វីគ្រប់យ៉ាងឱ្យអស់ពីលទ្ធភាពដែលយើងអាចធ្វើបាន នៅក្នុងការស្វែងរកអ្វីដែលត្រូវបានសន្យាថានឹងប្រទានឱ្យយើងទេឬអី?

គ្រាដំបូងនៃការស្ដារឡើងវិញ ខណៈដែលកិច្ចការដ៏អស្ចារ្យនេះរៀបនឹងបង្ហាញខ្លួននៅក្នុងចំណោមកូនចៅមនុស្ស នោះព្រះអម្ចាស់បានមានបន្ទូលថា : "ហេតុដូច្នេះហើយ ឱអ្នករាល់គ្នាដែលចាប់ផ្ដើមធ្វើការបំរើព្រះអើយ សូមឱ្យឃើញថា អ្នករាល់គ្នាបំរើទ្រង់ឱ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង ដើម្បីឱ្យអ្នករាល់គ្នាអាច បានឈរដោយឥតទោសនៅចំពោះព្រះ នៅថ្ងៃចុងក្រោយបំផុត"។4 ដោយអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់យើង---នោះគឺជាការនិយាយចេញអស់ពីក្នុងខ្លួន របស់យើង។

ប្រធាន ដាវីឌ អូ មិកឃេ បានប្រសាសន៍ថា រង្វាន់ដ៏ធំធេងកើតមានតែចំពោះពួកអ្នក ដែលបានពុះពារយ៉ាងក្លៀវក្លាប៉ុណ្ណោះ។5 រង្វាន់ទាំងនេះនឹងកើតមានចំពោះអស់អ្នកដែលបានចិញ្ចឹមបីបាច់ សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ ហើយធ្វើកិច្ចការ និងលះបង់ស្របទៅតាមឆន្ទៈរបស់ទ្រង់ ហើយផ្ដល់នូវអ្វីៗ ទាំងអស់ដែលពួកគេទទួលបានដើម្បីពង្រឹង និងស្ថាបនានគរព្រះ។

ការបំពេញនៃសេចក្ដីសន្យាដ៏ទេវភាពនេះ ដើម្បីមានជីវិតដ៏នៅអស់កល្បជានិច្ច ដើម្បីសំរេចបាននូវភាពល្អឥតខ្ចោះ និងភាពរីករាយជារៀងរហូតនៅក្នុងក្រុមគ្រួសារ គឺវាពឹងផ្អែកទៅលើការបង្ហាញសេចក្ដីជំនឿដ៏ស្មោះចំពោះព្រះយេស៊ូវគ្រីស្ទ ការគោរពតាមព្រះបញ្ញត្តិ សេចក្ដីខ្ជាប់ខ្ជួន និងការឧស្សាហ៍ព្យាយាមនៅក្នុងជីវិតរស់នៅរបស់យើង។

ព្រះអម្ចាស់ពុំបានរំពឹងទុកឱ្យយើងធ្វើអ្វីដែលយើងមិនអាចធ្វើបាននោះឡើយ។ បញ្ញត្តិដែលចង់ឱ្យបានល្អឥតខ្ចោះដូចជាទ្រង់នោះគឺលើកទឹកចិត្តយើងឱ្យធ្វើទៅតាមលទ្ធភាពរបស់យើង ដើម្បីស្វែងរក និងអភិវឌ្ឍទេពកោសល្យ និងឥរិយាបថ ដែលព្រះវរបិតាដ៏អស់កល្បជានិច្ចជាទីស្រឡាញ់បានប្រទានឱ្យយើង ដែលបានអញ្ជើញយើងឱ្យមកស្គាល់ពីសក្ដានុពលរបស់យើងក្នុងនាមជាកូនចៅនៃព្រះ។ ទ្រង់ស្គាល់យើង។ ទ្រង់ជ្រាបពីសមត្ថភាព និងដែនកំណត់របស់យើង។ ការអញ្ជើញ និងសំណូមពរឱ្យមានភាពល្អឥតខ្ចោះ និងដើម្បីសំរេចបាននូវជីវិតដ៏នៅអស់កល្បជានិច្ច គឺសំរាប់មនុស្សគ្រប់គ្នា។

បន្ទាប់ពីការបង្រៀនថា "មិនត្រូវឱ្យអ្នកណារត់លឿនជាងកម្លាំងដែលគេមាន" នោះស្ដេចបេនយ៉ាមីនបានគូសបញ្ជាក់បន្ថែមទៀតថា "ជាការចាំបាច់ឱ្យអ្នកនោះត្រូវព្យាយាម ដើម្បីគេអាចបានរង្វាន់"។ 6 ព្រះនឹងមិនតំរូវអ្វីឱ្យលើសពីលទ្ធភាពដែលយើងអាចធ្វើបាននោះឡើយ ពីព្រោះវាគឺជារឿងអយុត្តិធម៌ ប៉ុន្តែទ្រង់ក៏មិនព្រមទទួលយកនូវអ្វីដែលតិចជាងនោះដែរ ដោយសារវាគឺជារឿងអយុត្តិធម៌។ ហេតុដូច្នេះហើយ ចូរយើងធ្វើឱ្យអស់ពីលទ្ធភាពដើម្បីបំរើព្រះ និងមនុស្សដទៃទៀតឱ្យបានជានិច្ច។ ចូរយើងបំរើក្រុមគ្រួសាររបស់យើង និងធ្វើការហៅបំរើរបស់យើងនៅក្នុងសាសនាចក្រទៅតាមអ្វីដែលយើងអាចធ្វើបាន។ ចូរយើងធ្វើឱ្យអស់ពីសមត្ថភាព ហើយធ្វើខ្លួនឱ្យប្រសើរឡើងបន្តិចម្ដងៗជារៀងរាល់ថ្ងៃ។

សេចក្ដីសង្គ្រោះ និងជីវិតដ៏នៅអស់កល្បជានិច្ច នឹងមិនអាចកើតឡើងបានឡើយ បើគ្មានដង្វាយធួនរបស់ព្រះអង្គសង្គ្រោះរបស់យើងជាអង្គដែលយើងជំពាក់អ្វីគ្រប់យ៉ាងនោះ។ ប៉ុន្តែ ដើម្បីធ្វើឱ្យពរជ័យដ៏ធំមហិមានេះកើតមាននៅក្នុងជីវិតរបស់យើង នោះយើងគួរធ្វើនូវចំណែករបស់យើងជាមុនសិន "ត្បិតយើងដឹងថា មានតែដោយព្រះគុណទេ ទើបយើងបានសង្គ្រោះ បន្ទាប់ពីអ្វីៗទាំងអស់ដែលយើងអាចធ្វើបាន"។7 ចូរយើងធ្វើឱ្យអស់ពីលទ្ធភាពដែលយើងអាចធ្វើបានដើម្បីសំរេចនូវរឿងពិបាកៗទាំងឡាយ ជាមួយនឹងសេចក្ដីជំនឿ សេចក្ដីក្លៀវក្លា ការទទួលខុសត្រូវ និងសេចក្ដីស្រឡាញ់---នោះគឺការសំរេចបាននូវអ្វីដែលមនុស្ស គិតថាមិនអាចទៅ

បាន ប៉ុន្តែដោយមានអន្តរាគមន៍ពីសំណាក់ព្រះវរបិតាជាទីស្រឡាញ់ និងការបូជាដ៏គ្មានទីបញ្ចប់របស់ព្រះអង្គសង្គ្រោះរបស់យើង នោះវានឹងប្រែក្លាយទៅអំណោយទានដ៏មហិមាបំផុត ដែលជាជីវិតដ៏រុងរឿងបំផុតដោយរស់នៅជាមួយនឹងព្រះ និងក្រុមគ្រួសាររបស់យើងជារៀងរហូត ។

ខ្ញុំសូមអធិស្ឋានឱ្យយើងម្នាក់ៗនឹងចងចាំ ហើយរំលឹកឡើងវិញនូវការប្ដេជ្ញាចិត្តដែលយើងបានធ្វើជាមួយនឹងព្រះវរបិតាសួគ៌យើង នៅពេលយើងបានចុះទឹកនៃបុណ្យជ្រមុជ និងនៅពេលយើងបានទទួលពិធីនីមួយៗនៃដំណឹងល្អដែលបានស្ដារឡើងវិញ តាមរយៈការទទួលសាក្រាម៉ង់ដោយសក្ដិសម ។ ខ្ញុំសូមអធិស្ឋានថាយើងនឹងធ្វើឱ្យអស់ពីលទ្ធភាពរបស់យើងក្នុងនាមជា ស្វាមីភរិយា ជាឪពុកម្ដាយ ជាកូន ជាបងប្អូនប្រុសស្រី និងនៅក្នុងការហៅរបស់យើង ការចែកចាយដំណឹងល្អ ការជួយសង្គ្រោះដល់អ្នកដែលវសាត់អណ្ដែត ការធ្វើការសំរាប់សេចក្ដីសង្គ្រោះដល់បុព្វការីជនរបស់យើង និងនៅក្នុងកិច្ចការ និងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ។

ខ្ញុំសូមអធិស្ឋានថា ជីវិតរបស់យើងនឹងអនុញ្ញាតឱ្យយើងប្រកាស ដូចដែលសាវកប៉ុលបានធ្វើថា "ខ្ញុំបានតយុទ្ធយ៉ាងល្អ ខ្ញុំបានរត់ប្រណាំងជាស្រេច ខ្ញុំបានរក្សាសេចក្ដីជំនឿទៅហើយ" ។ 8

នៅពេលយើងធ្វើបែបនេះ នោះយើងនឹងបំពេញនូវតំរូវការដែលព្រះវរបិតាសួគ៌របស់យើងបានកំណត់ ដើម្បីប្រទានពរឱ្យយើងបានច្រើនជាងមុន នៅក្នុងជីវិតនេះ ក៏ដូចជានៅក្នុងជីវិតដ៏នៅអស់កល្បជានិច្ចផងដែរ ។ ទ្រង់សព្វព្រះទ័យចង់ប្រទានឱ្យយើងនូវរាល់អ្វីៗទាំងអស់ដែលទ្រង់មាន និងថែមទាំងអ្វីដែលធ្វើឱ្យយើងក្លាយទៅជាអ្នកទទួលបាននូវអំណោយទានដ៏អស្ចារ្យបំផុតរបស់ទ្រង់ ដែលជាជីវិតដ៏នៅអស់កល្បជានិច្ចនោះផងដែរ ។

ទោះបីជានៅក្នុងគំនិតរបស់យើងបានគិតថា ភាពល្អឥតខ្ចោះអាចលេចឡើងនូវឧបសគ្គមួយដែល មិនអាចនឹងប្រឈមមុខបាន ក្ដីខ្ញុំសូមធ្វើទីបន្ទាល់ថា ព្រះវរបិតា និងព្រះអង្គសង្គ្រោះរបស់យើងបានធ្វើឱ្យយើងដឹងថាគឺអាចនឹងប្រព្រឹត្តទៅបាន ។ ពិតណាស់ ជីវិតដ៏នៅអស់កល្បជានិច្ចគឺអាចនឹងសំរេចទៅបាន ។ មែនហើយ ភាពរីករាយសំរាប់ពេលនេះ និងជារៀងរហូតតទៅគឺអាចនឹងកើតឡើងបាន ។

ព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើង គឺជាមេសំរេចនៅក្នុងផែនការដ៏ល្អឥតខ្ចោះដែលមាននូវសេចក្ដីសន្យាដ៏រុងរឿងទាំងនេះ ហើយទ្រង់មានព្រះជន្មរស់ ។ ព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទបានលើកដាក់មកលើអង្គទ្រង់នូវអំពើបាបរបស់យើង និងភាពអយុត្តិធម៌ ដែលកើតមាននៅក្នុងពិភពលោកនេះ ដើម្បីយើងអាចរួចផុតពីលទ្ធផលនៃអំពើទាំងនោះ ។ ខ្ញុំដឹងថា ព្រះអម្ចាស់របស់យើង ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ។ ដំណឹងល្អ និងបព្វជិតភាពត្រូវបានស្ដារឡើងវិញមកកាន់ផែនដីនេះ សំរាប់សម័យចុងក្រោយ តាមរយៈព្យាការីយ៉ូសែប ស៊្មីធ ។ នៅថ្ងៃនេះ យើងមានពរជ័យយ៉ាងធំធេង ដោយមានពួកសាវក និងព្យាការីត្រូវបានហៅដោយព្រះ ដើម្បីដឹកនាំយើងនៅលើផ្លូវត្រឡប់ទៅឯព្រះវរបិតាយើងវិញ ។ ប្រធាន ថូម៉ាស អេស ម៉នសុន ត្រូវបានហៅឱ្យដឹកនាំកិច្ចការដ៏អស្ចារ្យនេះនៅក្នុងសម័យនេះ ។ លោកគឺជាព្យាការីនៃព្រះ ។ ខ្ញុំសូមធ្វើទីបន្ទាល់ពីកិច្ចការទាំងនេះ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. នីហ្វៃទី 3 12:48 ។

2. គ. និង ស. 14:7 ។

3. សូមមើល *Guide to the Scriptures* "Eternal Life" scripture.lds.org ។

4. គ. និង ស. 4:2 ។

5. សូមមើល *The Teachings of David O. McKay* រៀបរៀងដោយ Mary Jane Woodger (ឆ្នាំ 2004) ទំព័រ 300 ។

6. ម៉ូសាយ 4:27 ។

7. នីហ្វៃទី 2 25:23 ។

8. ធីម៉ូថេទី 2 4:7 ។